**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

## ព័ត៌មានពិស្តារនៃការដាក់ឯកសារ

**សំណុំរឿងលេខ** : ០០២/១៩-០៩-២០០៧-អវតក/អជសដ
**ដាក់ទៅ** : អង្គជំនុំជម្រះសាលាដំបូង
**ថ្ងៃដាក់** : ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៦
**ភាគីអ្នកដាក់** : សហព្រះរាជអាជ្ញា
**ភាសាដើម** : អង់គ្លេស

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 26-Apr-2016, 15:46
CMS/CFO: Sann Rada

## ចំណាត់ថ្នាក់ឯកសារ

**ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ:** **សាធារណៈ**

**ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង:** សាធារណៈ/Public

**ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:**

**ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ:**

**ឈ្មោះមន្ត្រីដែលបានពិនិត្យ:**

**ហត្ថលេខា:**

---

# ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់ នួន ជា និង ខៀវ សំផន សុំឲ្យទទួលយកភស្តុតាងអនុលោមតាមវិធាន៨៧(៤) នៃវិធានផ្ទៃក្នុង ទាក់ទងនឹងព្រះបរមរតនកោដ្ឋ សម្តេចឪ នរោត្តម សីហនុ

---

**អ្នកដាក់ឯកសារ:**

**សហព្រះរាជអាជ្ញា**
លោកស្រី ជា លាង
លោក Nicholas KOUMJIAN

**អ្នកទទួលឯកសារ:**

**អង្គជំនុំជម្រះសាលាដំបូង**
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម យ៉ា សុខន
ចៅក្រម Claudia FENZ
ចៅក្រម យូ ឧត្តរា

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:**
លោក ពេជ អង្គ
Marie GUIRAUD

**ចម្លងជូន:**

**ជនជាប់ចោទ**
នួន ជា
ខៀវ សំផន

**មេធាវីការពារក្តីជនជាប់ចោទ:**
លោក សុន អរុណ
លោក Victor KOPPE
លោក គង់ សំអុន
លោកស្រី Anta GUISSÉ

**ចម្លើយតប**

១. សហព្រះរាជអាជ្ញា សូមធ្វើការឆ្លើយតបទៅនឹងសំណើរបស់ នួន ជា អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង សុំឱ្យទទួលយកភស្តុតាងថ្មី ទាក់ទិននឹង ព្រះបរមរតនកោដ្ឋ ដែលបានជូនដំណឹង នៅថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៦ ("សំណើ")[1] ហើយក្រោយមក សំណើនោះមានការចូលរួម ដោយ ខៀវ សំផន ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០១៦[2]។ ចម្លើយតបរួមទៅនឹងសំណើទាំងពីរត្រឹម ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៦ ត្រូវបានអនុញ្ញាតដោយអង្គជំនុំជម្រះសាលាដំបូង ("អង្គជំនុំជម្រះ") នៅថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៦[3]។

២. នួន ជា បានស្នើឱ្យអង្គជំនុំជម្រះទទួលយកលិខិតចំនួនបីច្បាប់ ខ្សែវីដេអូមួយ និងខ្សែអាត់សំឡេង មួយ ដែលជាសេចក្តីថ្លែងការណ៍ធ្វើឡើងដោយព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ[4]។ ដើម្បីធ្វើ ឱ្យឯកសារទាំងនេះពាក់ព័ន្ធ នួន ជា បកស្រាយនូវអំណះអំណាងមួយដែលអ្នកជំនាញខាងការ សិក្សាស្រាវជ្រាវពីអំពើប្រល័យពូជសាសន៍ Alex Hinton បានឱ្យដឹងតាមរយៈសក្ខីកម្មរបស់គាត់ ថា (១) ទស្សនៈរបស់ ព្រះបរមរតនកោដ្ឋស្តីពីវៀតណាមនិងការឈ្លានពានរបស់វៀតណាម នៅកម្ពុជា មិនស៊ីសង្វាក់គ្នាទេ និង (២) ព្រះបរមរតនកោដ្ឋមិនធ្លាប់ប្រើពាក្យ "យួន"[5] ទេ។ ប្រសិទ្ធិភាពនៃអំណះអំណាងរបស់ នួន ជា គឺចង់បង្កប់ន័យថា ដោយសារតែសម្ភារៈដែលដាក់ជូន បង្ហាញឱ្យឃើញថាការផ្តល់យោបល់ទាំងពីរនេះមិនពិត នោះវាបន្ថយដល់តម្លៃដែលជាសក្ខីកម្ម របស់អ្នកជំនាញថា ជាចេតនារបស់ជនជាប់ចោទ និងមេដឹកនាំ បកក ដើម្បីញុះញង់ឱ្យស្អប់ និងការប្រើអំពីហិង្សាតាមរយៈការនិយាយសំដៅទៅលើចេតនារបស់វៀតណាម ដើម្បីដាក់បញ្ចូល កម្ពុជាជាសម្ព័ន្ធរបស់វៀតណាម និងតាមរយៈការនិយាយសំដៅទៅលើវៀតណាមថា "យួន"។

៣. ប៉ុន្តែ ការសន្និដ្ឋានដូច្នេះ មិនអាចទាញយកពីឯកសារទាំងនេះបានឡើយ។ អ្នកជំនាញ *មិន* ផ្តល់ ទស្សនៈយល់ឃើញរបស់ បរមរតនកោដ្ឋស្តីពីការកាន់កាប់របស់វៀតណាមថា មានភាពស៊ីសង្វាក់

---

[1] **E396** សំណើរបស់ នួន ជា អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង សុំឱ្យទទួលយកលិខិតចំនួនបីច្បាប់ ខ្សែវីដេអូមួយ និងខ្សែអាត់សំឡេងមួយ ទាក់ទិននឹងសម្តេចព្រះបរមកោដ្ឋ, ៨ មេសា ២០១៦។

[2] **E396/1** សំណើរបស់លោក ខៀវ សំផន អនុលោមតាមវិធាន៨៧(៤) នៃវិធានផ្ទៃក្នុង, ២០ មេសា ២០១៦, កថាខណ្ឌ៤។

[3] ចម្លើយតបរួមនេះ ត្រូវបានស្នើឡើងដោយការិយាល័យសហព្រះរាជអាជ្ញាតាមរយៈសារអេឡិចត្រូនិក នៅម៉ោង ០៧៤៣ នៅថ្ងៃសុក្រ ទី២២ ខែមេសា ឆ្នាំ២០១៦ (**ឯកសារភ្ជាប់ ១**) ដែលបានជំទាស់ដោយមេធាវីការពារក្តី នួន ជា តាមរយៈសារអេឡិច ត្រូនិក នៅម៉ោង ១០០១ (**ឯកសារភ្ជាប់ ២**) និងដែលបានអនុញ្ញាតដោយអង្គជំនុំជម្រះសាលាដំបូងតាមរយៈសារអេឡិចត្រូនិក របស់ Ken Roberts ដែលជាមន្ត្រីជាន់ខ្ពស់ទទួលបន្ទុកផ្នែកច្បាប់ នៅម៉ោង ១៣៤៥ (**ឯកសារភ្ជាប់ ៣**) ទាំងអស់ក្នុងថ្ងៃដដែល។

[4] **E396** សំណើ។

[5] **E396** សំណើ, កថាខណ្ឌ៤ និង៦។

គ្នាទេ ហើយគាត់ក៏មិនបានថ្លែងថា ព្រះបរមរតនកោដ្ឋ មិនធ្លាប់ប្រើពាក្យថា "យួន" នៅក្នុងសុន្ទរកថារបស់ព្រះអង្គដែរ លើកលែងតែសុន្ទរកថាមួយដែលព្រះអង្គបានធ្វើ ជូនក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ("UNSC") ក្នុងខែមករា ឆ្នាំ១៩៧៩។ មូលដ្ឋានរឹងមាំជាងនេះគឺថា ទស្សនៈរបស់ព្រះបរមរតនកោដ្ឋ អំពីចេតនារបស់វៀតណាមក្នុងការដាក់បញ្ចូលកម្ពុជាជាសម្ព័ន្ធរបស់ប្រទេសវៀតណាម នៅក្រោយសម័យកាលកម្ពុជាប្រជាធិបតេយ្យ និងការប្រើពាក្យ "យួន" ក្នុងសុន្ទរកថារបស់ព្រះអង្គចំពោះពួកគេ គឺមិនពាក់ព័ន្ធទៅនឹងសំណួរថាតើជនជាប់ចោទ និងមេដឹកនាំ បកក ដទៃទៀតមានចេតនាញុះញុងឲ្យស្អប់ និងការប្រើអំពើហិង្សាប្រឆាំងនឹងវៀតណាម នៅក្នុងសម័យកាលកម្ពុជាប្រជាធិបតេយ្យ ឬក៏អត់នោះឡើយ។

៤. ទីមួយ លិខិតទាំងបីច្បាប់ដែលបានសរសេរដោយព្រះបរមរតនកោដ្ឋ ជូននាយករដ្ឋមន្ត្រីវៀតណាម ផាន់ វ៉ាន់ដុង ក្នុងខែតុលា និងវិច្ឆិកា ១៩៧៩ ដែលព្រះអង្គបញ្ចេញការជំទាស់ទៅនឹងការកាន់កាប់ដែលកំពុងធ្វើនៅកម្ពុជាដោយវៀតណាម នៅក្នុងឆ្នាំ១៩៧៩ គឺគ្មានតម្លៃភវនីយភាព។ ការជំទាស់ទៅនឹង*ការកាន់កាប់* របស់វៀតណាមនៅក្នុងប្រទេសកម្ពុជា *នៅក្រោយ* ការដួលរលំ បកក គឺគ្មានការពាក់ពន្ធទាល់តែសោះ ក្នុងការកំណត់អំពីចេតនារបស់ជនជាប់ចោទដើម្បីប្រព្រឹត្តអំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មនានាប្រឆាំងជនជាតិវៀតណាម*នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ*។

៥. អំណះអំណាងរបស់ នួន ជា ដែលថា ការជំទាស់ដែលមាននៅក្នុងលិខិតទាំងបីច្បាប់នេះស្រដៀងគ្នាទៅនឹងការជំទាស់ ដែលបានធ្វើឡើងដោយព្រះបរមរតនកោដ្ឋ នៅឯ UNSC ក្នុងខែមករា ឆ្នាំ១៩៧៩ បន្ថយតម្លៃនៃសក្ខីកម្មរបស់ Alex Hinton នោះ គឺគ្មានមូលដ្ឋានទេ។ អ្នកជំនាញបានផ្តល់សក្ខីកម្មថា ព្រះបរមរតនកោដ្ឋ អាចស្ថិតក្រោមសម្ពាធចាប់បង្ខំណាមួយដោយ បកក ដើម្បីថ្លែងនូវសេចក្តីជំទាស់ដ៏ខ្លាំងក្លាដូច្នេះអំពីការកាន់កាប់របស់វៀតណាម នៅឯ UNSC ក៏ប៉ុន្តែអ្នកជំនាញបានថ្លែងថា គាត់មិនអាចផ្តល់ចម្លើយជាក់លាក់ណាមួយបានទេ[6]។ ចំណុចជាមូលដ្ឋានដែលសំខាន់ជាងនេះដែលបានដាក់ចំពោះអ្នកជំនាញដោយមេធាវីការពារក្តី នួន ជា - ដែលថា សេចក្តីថ្លែងការណ៍នៅ UNSC របស់ព្រះបរមរតនកោដ្ឋចំពោះវៀតណាម គឺដូចគ្នាទៅនឹងប្រភេទកំណត់ហេតុដែលបានធ្វើឡើងដោយ បកក ប្រឆាំងនឹងវៀតណាម - ត្រូវបានអ្នកជំនាញជំទាស់យ៉ាងពេញទំហឹង។

> "តាមពិត នៅក្នុងបរិបទនៃកម្ពុជាប្រជាធិបតេយ្យ ភ្លាមៗនៅបន្ទាប់ពីនោះ ការណ៍នេះគឺជារឿងខុសគ្នាច្រើនដែលមាននៅក្នុងចិត្តរបស់អ្នករាល់គ្នា។ ការណ៍នេះគឺច្បាស់ណាស់តាមរយៈវគ្គដែលលោកបានអាន។ បើយើងនិយាយអំពីចំណុចដែលយើងបានចាប់ផ្តើម

[6] **E1/404.1** ប្រតិចារឹក, ១៦ មីនា ២០១៦, ទំព័រ៣៥, 10.05.23។

កាលពីម្សិលមិញ អំពីថាតើការប្រើពាក្យ "យួន" ក្នុងបរិបទមួយដែលមានលក្ខណៈខ្លាំងជាង ព្រមទាំងជម្រុញ និងញុះញង់ឱ្យមានអំពើហិង្សាដូចយើងមានឧទាហរណ៍ជាច្រើនរួចមកហើយ -- រហូតមកដល់សព្វថ្ងៃនេះ យើងបានអនុវត្ត មួយទល់នឹង៣០ មានន័យថា យើងបាត់បង់មួយ, "យួន" បាត់បង់៣០ ដូច្នេះការបាត់បង់របស់យើងគឺ៣០ដងតិចជាងការបាត់បង់របស់ "យួន"។ លោកដឹងទេ ចំណុចនេះបានអានជូននៅក្នុងតុលាការហើយ។ ខ្ញុំមិនគិតថា ខ្ញុំចាំបាច់ត្រូវអានម្តងទៀតទេ ប៉ុន្តែប្រសិនបើលោក -- ខ្ញុំគ្រាន់តែ -- តើខ្ញុំអាចបញ្ចប់ត្រឹមហ្នឹងបានទេ?

ស.បាទ។ [10.01.51] ឆ។ ប្រសិនបើលោកលើកយកបរិបទនៃសុន្ទរកថានេះមកនិយាយពីកម្ពុជាប្រជាធិបតេយ្យ - គឺសុន្ទរកថាពីកម្ពុជាប្រជាធិបតេយ្យដែលខ្ញុំទើបបានអាន ដែលទើបបានបង្ហាញជាភស្តុតាង ហើយដោយយកសុន្ទរកថានេះ ប្រៀបធៀបជាមួយនឹងពាក្យដែលព្រះបរមរតនកោដ្ឋ បានមានបន្ទូលភ្លាមៗបន្ទាប់ពីការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ ក្នុងខណៈដែលព្រះអង្គកំពុងស្ថិតក្នុងសម្ពាធចាប់បង្ខំពីខ្មែរក្រហមនៅក្នុងពេលនោះ *វាហាក់ដូចជាខុសគ្នាខ្លាំងណាស់ចំពោះខ្ញុំ ដូច្នេះខ្ញុំគួរនិយាយថា វោហារសាស្ត្រដែលបានបញ្ចេញ ក្នុងការថ្លែងជាច្រើននៅក្នុងកម្ពុជាប្រជាធិបតេយ្យ ដូចជាពាក្យនេះជាដើម មានលក្ខណៈបង្កញុះញង់យ៉ាងខ្លាំងដែលនាំឱ្យមានអំពើហិង្សា និងថាវាមិនត្រូវឡើយដែលគេបានធ្វើការប្រៀបធៀបសុន្ទរកថាដែលបានថ្លែងដោយ ព្រះបរមរតនកោដ្ឋ។ ដើម្បីធ្វើការប្រៀបធៀបទាំងពីរនេះ -- ខ្ញុំចង់និយាយថា ខ្ញុំអាចបន្តអានអានេះ។ លោកអាចអានវាបាន។ ហើយវាខុសគ្នាទាំងស្រុង (សង្កត់ន័យត្រង់អក្សរទ្រេត)។*

៦. ដោយហេតុនេះ អក្សរទាំងបីតួនេះ គ្មានផ្តល់នូវតម្លៃភវនីយភាពនៅក្នុងការវាយតម្លៃលើការប្រព្រឹត្តិចំពោះជនជាតិវៀតណាម នៅក្នុងអំឡុងពេលកម្ពុជាប្រជាធិបតេយ្យ ដោយជនជាប់ចោទ និងពួកមេដឹកនាំ បកក ផ្សេងទៀតនោះទេ ហើយវាក៏មិនបានជួយនៅក្នុងការវាយតម្លៃពីភាពជឿជាក់បាននៃអ្នកជំនាញ នោះដែរ។

៧. ទីពីរ កំណត់ហេតុខ្សែវីដេអូ និងខ្សែអាត់សម្លេង ទាំងពីរនេះ ដែលមានសេចក្តីថ្លែងការណ៍ចំនួនពីររបស់អតីតសម្តេចឪ ដែលលោកបានប្រើប្រាស់នូវពាក្យថា "យួន" ក៏ពុំមានតម្លៃភវនីយភាពអ្វីដែរ។ សេចក្តីថ្លែងការណ៍ទាំងនេះ មិនត្រូវបានធ្វើឡើងដោយជនជាប់ចោទ ឬ មេដឹកនៃ បកក នោះទេ ហើយត្រូវបានធ្វើឡើង *នៅក្រោយ និង នៅខាងក្រៅនៃបរិបទរបបកម្ពុជាប្រជាធិបតេយ្យ។* ដូចដែលអ្នកជំនាញបានផ្តល់សក្ខីកម្មរួចហើយថា បរិបទនៃការប្រើពាក្យ "យួន" គឺមានសារៈសំខាន់ មិនគ្រាន់តែការប្រើប្រាស់ពាក្យនោះទេ គឺវាបានកំណត់ថាតើពាក្យនោះត្រូវបានប្រើប្រាស់

ក្នុងគោលបំណងដើម្បីញុះញង់ឲ្យមានការស្អប់ខ្ពើម និងមានហិង្សានៅក្នុងអំឡុងពេលនៃកម្ពុជាប្រជាធិបតេយ្យ,

> "ដូចខ្ញុំជម្រាបជូនខាងដើម ពាក្យ "យួន" នេះ នៅពេលនោះអាចប្រើប្រាស់បានដែលពេលនោះ គឺថាមិនមានការរើសអើងដល់ថ្នាក់របៀបនេះនោះទេ។ ខ្ញុំបង្ហាញច្បាស់ហើយតាំងពីដើមទីមកថា ដើម្បីឲ្យយល់អំពីការប្រើប្រាស់ពាក្យ "យួន" នៅក្នុងបរិបទកម្ពុជាប្រជាធិបតេយ្យ នៅពេលដែលពាក្យហ្នឹង គេប្រើនៅក្នុងលក្ខណៈជាមនោគមន៍វិជ្ជា ដើម្បីញុះញង់ឲ្យ មានការស្អប់ គឺគេប្រើប្រាស់នៅក្នុងសម័យសាធារណរដ្ឋ ហើយនៅក្នុងបរិបទនយោបាយ គឺសំដៅទៅលើជនជាតិវៀតណាមក្នុងលក្ខណៈទ្រង់ទ្រាយធំ ដើម្បីឲ្យស្អប់ និងដើម្បី ញុះញង់ឲ្យមានការស្អប់តាមរយៈការផ្សព្វផ្សាយជាសារនយោបាយ និងជាការឃោសនា។ ហើយពាក់ព័ន្ធទៅនឹងការបោសសម្អាត ដកឫសខ្មាំង គឺវាមានការប្រើប្រាស់ពាក្យនេះដើម្បី ដុតកំហឹងទៅលើជនជាតិវៀតណាម។ ខ្ញុំបាននិយាយហើយពាក្យប្រើប្រាស់យួននេះ គឺ សំដៅទៅលើជាតិសាសន៍ ភាសា ហើយនិងការដែល គេហៅថាការស្អប់ខ្ពើមចំពោះជនជាតិវៀតណាម។ ដូចខ្ញុំបានលើកពីខាងដើម វាអាចមានការប្រើប្រាស់ពាក្យ "យួន" ដោយថា មិនបានគិតថាវាយ៉ាងណាយ៉ាងណីនោះទេ វាអាច។ ក៏ប៉ុន្តែក្នុងបរិបទធំនោះ ទូលំទូលាយនោះ គឺជាការរើសអើងហើយ ក៏ប៉ុន្តែពាក្យនេះក៏វាអាចប្រើប្រាស់ខុសគ្នាដែរ"[7]។

> "នៅចុងបញ្ចប់ ជំហររបស់ខ្ញុំគឺថា បញ្ជាក់យ៉ាងច្បាស់ថា ពាក្យ "យួន" អាចជាពាក្យប្រើប្រាស់ន័យខុសៗគ្នា ជាពាក្យដែល*អាច* ញុះញង់ឲ្យមានកំហឹង និងអំពើហិង្សា *ហើយក្នុង បរិបទកម្ពុជាប្រជាធិបតេយ្យ* គឺជាពាក្យដែលញុះញង់ ឲ្យកើតមាននូវអំពើប្រល័យពូជ សាសន៍ហើយ។ *(សង្កត់ន័យបន្ថែមដោយអក្សរទ្រេត)*"[8]។

៨. ដោយសារបរិបទផ្សេងគ្នា គោលបំណង និងពេលវេលា ដែលនៅក្នុងនោះសុន្ទរកថារបស់អតីតសម្តេចឪ ត្រូវបានផ្តល់នោះ សុន្ទរកថានោះពុំមានតម្លៃភស្តុតាងនៅក្នុងការកំណត់ថាតើ ជនជាប់ចោទ ឬពួកមេដឹកនាំ បកក ផ្សេងទៀតបានប្រើប្រាស់ពាក្យ "យួន" នេះដោយភ្ជាប់ទៅនឹង ភាសា និងនយោបាយដទៃទៀត នៅក្នុងអំឡុងពេលនៃកម្ពុជាប្រជាធិបតេយ្យ ដើម្បីញុះញង់ឲ្យមានការស្អប់ខ្ពើមជាតិសាសន៍ និងមានហិង្សាប្រឆាំងនឹងជនជាតិវៀតណាម។ លើសពីនេះ ថាតើសុន្ទរកថារបស់អតីតសម្តេចឪ បានប្រើនូវភាសាប្រកាន់ជាតិសាសន៍ចំពោះជនជាតិវៀតណាម តាមរយៈការ

---

[7] **E1/404.1** ប្រតិចារឹក, ១៧ មីនា ២០១៦, ទំព័រ ៦៤, ម៉ោង 11.27.42 – 11.30.22.

[8] **E1/404.1** ប្រតិចារឹក, ១៧ មីនា ២០១៦, ទំព័រ ៨៣, ម៉ោង 12.10.24 – 12.11.14.

ប្រើប្រាស់នូវពាក្យថា“យួន” គឺពាក់ព័ន្ធទៅនឹងការកំណត់នៃបទចោទនានាប្រឆាំងនឹងជនជាប់ចោទដែរឬមួយយ៉ាងណា។

៩. អំណះអំណាងរបស់ ខៀវ សំផន ផ្ទុះបញ្ចាំងយ៉ាងទូលំទូលាយនូវអំណះអំណាងរបស់ នួន ជា។ យ៉ាងណាក៏ដោយ គាត់បានលើកថែមទៀតដោយបានថ្លែងថា សម្ភារៈដែលបានដាក់ស្នើដោយ នួន ជា គឺ “ផ្ទុយគ្នាទាំងស្រុង” ទៅនឹងភស្តុតាងរបស់ Alex Hinton[9]។ ចំពោះហេតុផលដូចដែលបានលើកឡើងនៅខាងលើ ភស្តុតាងដែលបានដាក់ស្នើនេះ មិនផ្ទុយគ្នាទៅនឹងភស្តុតាងរបស់អ្នកជំនាញ Hinton ទេ។

១០. អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញា សូមស្នើឱ្យ អង្គជំនុំជម្រះសាលាដំបូង បដិសេធសំណើរបស់មេធាវីការពារក្ដីដែលសុំឱ្យទទួលយកភស្តុតាងទាំងនេះ។ ភស្តុតាងទាំងនេះគឺមិនពាក់ព័ន្ធទៅនឹងការកំណត់បទចោទនានានៅក្នុងដីកាចោទប្រកាន់ដែលទាក់ទងនឹងការព្រឹត្តិទៅលើជនជាតិវៀតណាម ហើយនិងមិនប្រឆាំងទៅនឹងភាពអាចជឿជាក់បានរបស់សាក្សីជំនាញ Alex Hinton នោះឡើយ៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៦ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | [signature] |
| | **លោក Nicholas KOUMJIAN**<br>សហព្រះរាជអាជ្ញា | | [signature] |

[9] **E396/1** សំណើរបស់ ខៀវ សំផន, ២០ មេសា ២០១៦, កថាខណ្ឌ ៩។